# កិច្ចប្រជុំបណ្ដាញក្រុមកសិករស្រាវជ្រាវ

នៅថ្ងៃទី ០១-០២ ខែ មិថុនា ឆ្នាំ ២០១០ វិទ្យាស្ថានសេដាកដើម្បីអភិវឌ្ឍន៍មូលដ្ឋាន សហការជាមួយកម្មវិធីប្រូលីណូវ៉ាកម្ពុជា បានរៀបចំកិច្ចប្រជុំបណ្ដាញក្រុមកសិករស្រាវជ្រាវ ដើម្បីជំរុញការងារពិសោធន៍ និងការរុករកគំនិតថ្មីឱ្យកាន់តែមានភាព ទូលំទូលាយ និងច្បាស់លាស់ថែមទៀត ពិសេសនៅរដូវវស្សាខាងមុខ។ កសិករពិសោធន៍ចំនួន ៤៥នាក់មកពីខេត្តចំនួន ១០ទូទាំងប្រទេសកម្ពុជានឹងធ្វើការ បង្ហាញនូវផែនការពិសោធន៍ និងស្រាវជ្រាវរុករកនូវគំនិតថ្មីទាក់ទងនឹងផលិតកម្មកសិកម្មដូចជា ស្រូវ បន្លែ និងការចិញ្ចឹមសត្វ នៅរដូវវស្សាខាងមុខ។

ជាលទ្ធផល កសិករបានបង្ហាញនូវផែនការពិសោធន៍ទៅលើប្រធានបទថ្មីៗជាច្រើនទៅដល់កសិករចូលរួមក៏ដូចជាអ្នកសារព័ត៌មានដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ដែលរួមមានប្រធានបទ:

- ការពិសោធន៍ចិញ្ចឹមមាន់ដោយប្រើចំណីធម្មតា និងចំណីទិញពីផ្សារ
- ការបង្កាតពូជអន្ទង់យកពូជ
- ការធ្វើប.វ.ស ដោយស្ទូង ១ដើម និង ២ដើម
- ការបន្សុតពូជស្រូវក្រោកពង្ស
- ការធ្វើជីកំប៉ុស្តន៍ទឹក និងកំប៉ុស្តន៍គោក
- ការដាំផ្សិតចំបើងធម្មតា និងផ្សិតចំបើងចំហុយ
- ការធ្វើមេជីទឹកផលិតពីទំពាំង ស្ករត្នោត និងទឹកដូង
- និងការស្ទូងមិនភ្ជួរដីជាដើម ។ល។

គួររំលឹកថា ប្រូលីណូវ៉ាកម្ពុជាបានចាប់ផ្តើមឡើងនៅឆ្នាំ ២០០៤ បច្ចុប្បន្នមានស្ថាប័ន ២១ ចូលរួម គឺអង្គការមិនមែនរដ្ឋាភិបាល ៤ (សេដាក ស្រែខ្មែរ អភិវឌ្ឍន៍ស្ត្រី និងប៉ាដិក) មន្ទីរកសិកម្មខេត្ត ១០ (តាកែវ ស្វាយរៀង កំពង់ឆ្នាំង ព្រៃវែង កំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង និងកណ្ដាល) នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានដំណាំស្រូវនៃអគ្គនាយក ដ្ឋានកសិកម្ម ស្ថាប័នអប់រំ ៣ គឺ សាលាជាតិកសិកម្មកំពង់ចាម សាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យភូមិន្ទកសិកម្ម ស្ថាប័នកសិករ ២ (បណ្ដាញកសិករ និងធម្មជាតិ និងក្រុមប្រឹក្សាឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ)។

គោលបំណងសំខាន់របស់ក្រុមការងារប្រូលីណូវ៉ាកម្ពុជាគឺ បង្កើតភាពជាដៃគូអន្តរស្ថាប័ន ដើម្បីជំរុញគំនិតថ្មីក្នុង មូលដ្ឋានវិធីសាស្ត្រចូលរួមក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម ព្រមទាំងជំរុញឱ្យមានវិធីសាស្ត្រចូលរួមក្នុងការ ស្រាវជ្រាវ ផ្សព្វផ្សាយ និងការអប់រំកសិកម្មដល់ស្ថាប័ននានា។

